# ដំណើរការនៃការហៅទូរស័ព្ទ លេខសូន្យបីដង (000)

## ជានិច្ចកាល សូមហៅទូរស័ព្ទ លេខសូន្យបីដង (000) នៅគ្រាអាសន្ន



### ជំហានទី 1

អ្នកទទួលទូរស័ព្ទនឹងសួរអ្នកថាតើអ្នកត្រូវការសេវាកម្មណាមួយ៖ ប៉ូលីស ក្រុមពន្លត់អគ្គីភ័យ ឬក៏រថយន្តសង្គ្រោះ?

**ប្រសិនបើអ្នកត្រូវការអ្នកបកប្រែ សូមប្រាប់ភាសាដែលអ្នកត្រូវការ ជាភាសាអង់គ្លេស**





### ជំហានទី 2

អ្នកទទួលទូរស័ព្ទនឹងភ្ជាប់អ្នកទៅនឹងមជ្ឈមណ្ឌលទាក់ទងនៅគ្រាអាសន្នមួយរបស់ ESTA។

អ្នកទទួលទូរស័ព្ទនឹងសួរអ្នកថា៖

**តើអ្នកត្រូវការប៉ូលីស ក្រុមពន្លត់អគ្គីភ័យ ឬក៏រថយន្តសង្គ្រោះ នៅកន្លែងណា?**

នេះជាព័ត៌មានដ៏សំខាន់ជាងគេ។

អ្នកទទួលទូរស័ព្ទបញ្ជាក់អាសយដ្ឋានដោយសួរថាតើផ្លូវឆ្លងកាត់ជិតជាងគេបង្អស់នៅកន្លែងណា ឬសួររកកន្លែងដែលងាយមើលឃើញមួយ។

បន្ទាប់មក អ្នកទទួលទូរស័ព្ទនឹងសួរអ្នកថា៖

**តើអ្នកមានគ្រោះអាសន្នអ្វីដែរ?**

នៅពេលអ្នកទទួលទូរស័ព្ទដឹងពីទីកន្លែង និងប្រភេទនៃគ្រោះអាសន្នហើយ គេនឹងរៀបចំឲ្យមានជំនួយភ្លាម។

### ជំហានទី 3

អ្នកទទួលទូរស័ព្ទនឹងបន្តសួរសំណួរបន្ថែមដើម្បីប្រមូលព័ត៌មានឲ្យបានច្រើនដែលអាចធ្វើទៅបាន។

ការសួរនេះនឹងមិនធ្វើឲ្យមានការយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងការសង្គ្រោះបន្ទាន់ទេ។



www.esta.vic.gov.au | /Esta000 | @ESTA000 | @esta_000 | search 'ESTA000'

ESTA 000
Saving Time Saving Lives